## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែធ្នូ

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត (Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៣រូប និងតាមប្រព័ន្ធអនឡាយចំនួន២៨រូប សរុបចំនួន៦១រូប។

**៤. របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

៤.២-បទបង្ហាញស្តីពីផែនការសកម្មភាពអាទិភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ក្រុមប្រឹក្សាបច្ចេកទេសសម្រាប់ឆ្នាំ២០២៤។

៤.៣- មតិបូកសរុប និងបិទកម្មវិធី

ដំណើរការកិច្ចប្រជុំ និងការបង្ហាញដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែធ្នូ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បង្ហាញជូនអង្គប្រជុំស្តីពី «ផែនការសកម្មភាពអាទិភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ក្រុមប្រឹក្សាបច្ចេកទេសសម្រាប់ ឆ្នាំ២០២៤»។ ឯកឧត្តម បានបញ្ជាក់ថា លទ្ធផលការងារឆ្នាំ២០២៣ ដែលបានបង្ហាញក្នុងកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២៣ ដើម្បីឆ្ពោះទៅសម្រេចគោលដៅ ៩៥ ៩៥ ៩៥ យកប្រជាជនជាស្នូល។សកម្មភាពដែលបានយកមកបង្ហាញមាន៖

- ភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេស ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចែងក្នុងមាត្រា១៨ និងមាត្រា១៩។

សង្ខេបស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០២៣មាន៖

- អត្រាវិជ្ជមានមេរោគអេដស៍តាមក្រុមប្រជាជនគន្លឹះមាន ក្រុមស្ត្រីបម្រើតាមសេវាកម្សាន្តសប្បាយ ៤,៩% បុរសរួមភេទជាមួយបុរស៥,៥% និងក្រុមបំប្លែងភេទ១៣,៥% ក្រុមអ្នកប្រើប្រាស់គ្រឿងញៀនដោយជក់៥,៧% និងក្រុមប្រើប្រាស់គ្រឿងញៀន១៥,២%។
- ការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រីថយចុះគួរឱ្យកត់សំគាល់ ប៉ុន្តែមានការកើនឡើងក្នុងចំណោមបុរសរួមភេទជាមួយបុរស។
- វឌ្ឍនភាពធៀបនឹងគោលដៅ ៩៥ ៩៥ ៩៥ ទី១ ទទួលបាន៨៦% ទី២ ទទួលបាន៩៩% និងទី៣ ទទួលបាន៩៨%។
- ភាគរយនៃចំណេះដឹងអំពីការការពារមេរោគអេដស៍ក្នុងចំណោមយុវវ័យទាំងពីរភេទ អាយុពី ១៥ឆ្នាំ ទៅ២៤ឆ្នាំ មានកម្រិតទាប។

## បញ្ហាប្រឈមនៃការអនុវត្តការងារឆ្នាំ២០២៣

- មិនទាន់សម្រេចបានគោលដៅ៩៥ទី១ និងការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ ដោយការកាត់បន្ថយករណីឆ្លងថ្មីក្រោម២៥០នាក់ក្នុង១ឆ្នាំ។ ភាពមិនស្មើគ្នាក្នុងការទទួលបានសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ និងសេវាព្យាបាល និងអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូននៅមានកម្រិតខ្ពស់។
- ជំរុញបទអន្តរាគមន៍ផ្តោតលើការបង្ការ និងការស្វែងរកករណីអ្នកផ្ទុកមេរោគអេដស៍។
- ការកើនឡើងការឆ្លងថ្មីក្នុងចំណោមបុរស ក្រុមប្រជាជនគន្លឹះ និងដៃគូរបស់ពួកគេ (ជាពិសេសក្រុមយុវវ័យ) ដែលជាក្រុមពិបាកជួប (hard to reach group) និងមានឥរិយាបទប្រព្រឹត្តប្រឈមខ្ពស់ (chemsex) និងក្រុមចល័ត។
  - ពង្រីក និងពង្រឹងសេវាបង្ការដែលមានស្រាប់ និងសេវាធ្វើតេស្តឈាមដល់ក្រុមប្រឈមទាំងនោះជាមួយសេវាប្រកបដោយមេត្រីភាព និងវិធីសាស្ត្រផ្សេងៗប្រកបដោយនវានុវត្តន៍ (e.g. KP-friendly services, long- acting PrEP, virtual and mobile out-reach, PDI+, HIVST etc.)
  - ពង្រឹងការតាមរកករណីជំងឺកាមរោគ សេវាថែទាំ និងព្យាបាល។
  - បង្កើតសេវាបន្ថែមឆ្លើយតបតាមតម្រូវការរបស់ក្រុមទាំងនោះ។
- មានការថយចុះបន្ថែមទៀតការបោះបង់ចោលការព្យាបាល LTFU និងការស្លាប់ក្នុងចំណោមអ្នកកំពុងទទួលសេវាលព្យាបាល និង ថែទាំ។
  - បន្តអនុវត្តគោលនយោបាយធ្វើតេស្តរកមេរោគអេដស៍ និងព្យាបាល (Test and treat policy) ការត្រួតពិនិត្យបន្ទុកមេរោគអេដស៍ ការផ្តល់សេវាទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ (MMD, CAD), peer support network, client- friendly services with patient satisfactory feedback.
  - ផ្តោតការយកចិត្តទុកដាក់លើជំងឺផ្សេងៗដែលបង្កឱ្យស្លាប់ ដោយរួមបញ្ចូលសេវាសុខភាពផ្លូវចិត្ត និងជំងឺមិនឆ្លងផ្សេងៗ។
  - អនុវត្តវិធីសាស្ត្រគ្រប់គ្រងសកម្មករណីផ្ទុកមេរោគអេដស៍ (active case management) សម្រាប់អ្នកខកខានការណាត់ជួប ឬអ្នកមានបន្ទុកមេរោគអេដស៍ខ្ពស់។

## ទិសដៅ និងសកម្មភាពចម្បងៗសម្រាប់ជំហានបន្ទាប់ (ឆ្នាំ២០២៤)

- អនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៣
  - ជំរុញការផ្តល់ចំណេះដឹងស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការជំរុញការចូលរួមពីក្រុមយុវវ័យក្នុងការងារបង្ការ ការធ្វើតេស្តឈាមរកមេរោគអេដស៍ ឱ្យបានទូលំ

ទូលាយ ដោយការអនុវត្តសកម្មភាពអប់រំសុខភាពផ្លូវភេទទូលំទូលាយ (Comprehensive Sexual Education) ក្នុងវិស័យអប់រំ ។

- ជំរុញការអនុវត្តផែនការសកម្មភាពកាត់បន្ថយការមាក់ងាយ និងការរើសអើង (Stigma and Discrimination)ក្នុងវិស័យសុខាភិបាល អប់រំ និងសហគមន៍។
- សម្របសម្រួលការអនុវត្តឱ្យមានប្រសិទ្ធភាព នូវគម្រោងផែនការសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២៤-២០២៦ ដែលជាការចូលរួមពីហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល មូលនិធិសកល និងមូលនិធិផ្សេងៗទៀត។
- ជំរុញភាពជាម្ចាស់ក្នុងការដឹកនាំសម្របសម្រួលការឆ្លើយតបមេរោគអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបន្តអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cites: Ending the AIDS Epidemic) និងខេត្តដែលទទួលបានថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន៨០លានរៀល (៤ខេត្ត) ចំនួន៦០លានរៀល (១១ខេត្ត) និង៤០លានរៀល (១០ខេត្ត)។
- ជំរុញការរៀបចំអនុវត្តផែនការសកម្មភាព ថវិកា តាមក្រសួង ស្ថាប័ន ស្របតាមផែនការយុទ្ធសាស្ត្រជាតិលើកទី៦។
- បន្តកៀរគរហិរញ្ញប្បទានក្នុងស្រុក និងក្រៅស្រុក និងកំណត់អាទិភាពសកម្មភាពសម្រាប់ពង្រឹងប្រព័ន្ធជាតិ (Country System) ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពិសេសសម្រាប់ការងារឆ្លើយតបនឹងមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ។
- បន្តជំរុញការគាំទ្រសង្គម ដល់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ។
- បន្តជំរុញអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
- ផ្សព្វផ្សាយ និងជំរុញការអនុវត្តឱ្យបានទូលំទូលាយ ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ សម្រាប់ឆ្នាំ២០២៤-២០២៨ ។
- សម្របសម្រួលការរៀបចំផែនការប្រតិបត្តិ (Operational Pan) សម្រាប់ផែនការយុទ្ធសាស្ត្រជាតិលើកទី៦ និងផែនទីបង្ហាញផ្លូវសម្រាប់និរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍នៅកម្ពុជា (SRM)។
- បញ្ចប់ការតាក់តែងគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ និងចីរភាពកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨។

- បញ្ចប់ការប៉ាន់ប្រមាណការចំណាយក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ (NASA 7)។
- បញ្ចប់កំណត់ពន្យល់ស្តីពីមាត្រា ១៨ ១៩ ៣៤ ៣៥ នៃច្បាប់បង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រួលដល់បទអន្តរាគមន៍បង្ការ និងជំរុញការធ្វើតេស្តឈាមរកមេរោគអេដស៍ ក្នុងចំណោមយុវវ័យអាយុ១៥ឡើង។
- ការធ្វើការប៉ាន់ប្រមាណមេរោគអេដស៍ថ្នាក់ជាតិ (National HIV Estimates 2024) ដោយប្រើប្រាស់ទិន្នន័យ (HIV Prevention Road Map)។
- សម្របសម្រួលការរៀបចំផែនទីបង្ហាញផ្លូវផ្តោតលើការបង្ការការចម្លងមេរោគអេដស៍។
- បន្តពង្រឹងប្រព័ន្ធព័ត៌មានយុទ្ធសាស្ត្រ (Strategic Information) ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (NAA Consolidated HIV Dashboard, CLM Plus S&D, Database on Social Protection..)។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រីថយចុះគួរឱ្យកត់សំគាល់ ប៉ុន្តែមានការកើនឡើងក្នុងចំណោមបុរសរួមភេទជាមួយបុរសគួរឱ្យបារម្ភ។ ដូចនេះយើងទាំងអស់គ្នា ត្រូវតែរកវិធីសាស្ត្រយ៉ាងណា ដើម្បីឱ្យថយចុះសមស្របនឹងសមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង និងលើកយកទៅចូលក្នុងកិច្ចប្រជុំពេញអង្គខាងមុខ ។ ឯកឧត្តមក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់

នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការបង្ការការចម្លងមេរោគអេដស៍ ដល់គ្រប់មជ្ឈដ្ឋាន ជាពិសេសក្រុមយុវវ័យ។

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំថោះបញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ** | អ្នកធ្វើរបាយការណ៍

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម ឃឹនដារ៉េត**